ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល
លេខ.០១៤១.....សស.សក/សសររ

# សេចក្តីសម្រេច
# ស្តីពី
# ការទទួលស្គាល់មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំជាគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា៥ មាត្រា៧ មាត្រា១២ មាត្រា១៧ នៃអនុក្រឹត្យលេខ២១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៧ និងមាត្រា៦ ថ្មីនៃអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញប្រកាសលេខ ២៨១ អបស.អធម/ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការកែសម្រួលកម្មវិធីសិក្សាជាតិថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាកនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- បានឃើញប្រកាសលេខ ០៧៨ អបស.អធម/ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីស្តង់ដាអប្បបរមានៃគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិក សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសុខាភិបាល



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# សម្រេច

**ប្រការ១ .‒**

ត្រូវបានទទួលស្គាល់ **មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ** ជាគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក ដែលមានសមត្ថភាពទទួលនិស្សិតចុះកម្មសិក្សាគ្លីនិកចំនួន៣៥នាក់ ក្នុងមួយវេន។

**ប្រការ២ .‒**

សេចក្តីសម្រេចស្តីពីការទទួលស្គាល់នេះ មានសុពលភាពរយៈពេល ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា។ មន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ ត្រូវស្នើសុំការវាយតម្លៃឡើងវិញពីក្រសួងសុខាភិបាលដើម្បីបន្តសុពលភាពឱ្យបានយ៉ាងតិច២(ពីរ)ខែមុនកាលបរិច្ឆេទផុតកំណត់។

**ប្រការ៣.‒**

ក្នុងករណីមន្ទីរពេទ្យមិនអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងប្រកាសលេខ០៧៨ អបស.អធម/ប្រក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីស្តង់ដាអប្បបរមានៃគ្រឹះស្ថានសម្ព័ន្ធទ្រទ្រង់កម្មសិក្សាគ្លីនិកសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្ររងគិលានុបដ្ឋាក ក្រសួងសុខាភិបាលមានសិទ្ធិដកហូតសេចក្តីសម្រេចនេះ។

**ប្រការ៤ .‒**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥ .‒**

អគ្គនាយកបច្ចេកទេសសុខាភិបាល ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងប្រធានមន្ទីរពេទ្យបង្អែកខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

សាស្ត្រាចារ្យ **ឈាន រ៉ា**

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមសាស្ត្រាចារ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ធំ
- គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ